TRANSPARENCY INTERNATIONAL
the global coalition against corruption

# សេចក្តីថ្លែងការណ៍ព័ត៌មាន

## អង្គការតម្លាភាពអន្តរជាតិថ្កោលទោសយ៉ាងធ្ងន់ធ្ងរចំពោះការធ្វើឃាត បណ្ឌិត កែម ឡី និងទាមទារឲ្យមានការស៊ើបអង្កេតឯករាជ្យ

ទីក្រុងប៊ែរឡាំង –ថ្ងៃទី១២ ខែ កក្កដា ឆ្នាំ២០១៦

**អង្គការតម្លាភាពអន្តរជាតិ** សូមធ្វើការថ្កោលទោសយ៉ាងធ្ងន់ធ្ងរចំពោះការធ្វើឃាត **លោកបណ្ឌិត កែម ឡី** ដែលជាអ្នកវិភាគឯករាជ្យ និងជាអ្នករិះគន់រដ្ឋាភិបាលដ៏ល្បីល្បាញមួយរូបនៅក្នុងប្រទេសកម្ពុជា។

កាលពីព្រឹកថ្ងៃអាទិត្យ **លោកបណ្ឌិត កែម ឡី** ត្រូវបានបាញ់សម្លាប់ នៅទីក្រុងភ្នំពេញ រាជធានីនៃប្រទេសកម្ពុជា។ យើងទាមទារឲ្យមានការស៊ើបអង្កេត ដោយឯករាជ្យ តម្លាភាព និង ហ្មត់ចត់លើឃាតកម្មដ៏យង់ឃ្នងមួយនេះ។

**អង្គការតម្លាភាពអន្តរជាតិ** បានសំដែងក្តីព្រួយបារម្ភពីកំនើននៃការរឹតបណ្តឹងចំពោះអង្គការសង្គមស៊ីវិល និងការយាយីចំពោះសកម្មជនសិទ្ធមនុស្ស និងប្រឆាំងអំពើពុករលួយនៅក្នុងប្រទេសកម្ពុជា។ មួយឆ្នាំកន្លងទៅ អង្គការតម្លាភាពអន្តរជាតិបានប្រមានអំពីផលប៉ះដ៏ធ្ងន់ធ្ងរដែលបណ្តាលមកពី ច្បាប់ស្តីពីសមាគម និងអង្គការក្រៅរដ្ឋាភិបាលចំពោះលទ្ធភាពរបស់ប្រទេសមួយនេះក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ និង ការបង្កឧបសគ្គដល់ការប្រើសិទ្ធិសេរីភាពរបស់អង្គការសង្គមស៊ីវិល។ ដប់សប្តាហ៏កន្លងទៅនេះ**អង្គការតម្លាភាពអន្តរជាតិ** បានអំពាវនាវដល់អាជ្ញាធរឲ្យបញ្ឈប់ការយាយីដល់មន្ត្រីអង្គការសង្គមស៊ីវិលផងដែរ។

ក្នុងមាត្រាទី១៣នៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយដែលប្រទេសកម្ពុជាបាន ផ្តល់សច្ចាប័នកាលពីឆ្នាំ២០០៧ ដែលតម្រូវឲ្យរដ្ឋាភិបាលមានយន្តការត្រឹមត្រូវដើម្បីលើកកម្ពស់ការចូលរួមយ៉ាងសកម្មពីសំណាក់បុគ្គល និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ។ ក្រុមទាំងនេះរួមមាន សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍នានាដែលធ្វើកិច្ចការទប់ស្កាប់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ជាថ្មីម្តងទៀតអង្គការតម្លាភាពអន្តរជាតិអំពាវនាវដល់អាជ្ញាធរកម្ពុជាគ្រប់ជាន់ថ្នាក់ធ្វើការស៊ើបអង្កេតដោយឯករាជ្យទាក់ទងនឹងករណីឃាតកម្ម**លោកបណ្ឌិត កែម ឡី** និង អំពាវនាវដល់អាជ្ញាធរកម្ពុជាបញ្ឈប់ការយាយី ដល់អង្គការសង្គមស៊ីវិល និងគោរពទៅតាមកិច្ចព្រមព្រៀងនៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ(UNCAC) ។

ទំនាក់ទំនងសំភាសន៍៖

លោក គ្រីស សានដឺ (Chris Sanders)

ទូរស័ព្ទ: +49 30 34 38 20 666
អ៊ីម៉ែល: press@transparency.org